# សហគមន៍ខ្មែរកម្ពុជាក្រោម
# KHMER KAMPUCHEA KROM COMMUNITY
# LA COMMUNAUTÉ DU KHMER KAMPUCHEA KROM

## លិខិតចូលរួមមរណៈទុក្ខ

### ជូន

### លោកស្រី និងគ្រួសារសពលោក សឺន ទូន

### អតីតនាយកប្រតិបត្តិសហព័ន្ធខ្មែរកម្ពុជាក្រោមពិភពលោក

សហគមន៍ខ្មែរកម្ពុជាក្រោម មានសេចក្ដីតក់ស្លុតរន្ធត់ចិត្តយ៉ាងខ្លាំង និងសោកស្ដាយឥតឧបមា នៅពេលដែលទទួលបានពតិមានដ៏ក្រៀមក្រំបំផុតអំពីមរណៈភាពរបស់លោកសឺន ទូន អតីតនាយកប្រតិបត្តិសហព័ន្ធខ្មែរកម្ពុជាក្រោមពិភពលោកនៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៧ ដោយរោគាពាធ ។

ក្នុងនាមសហគមន៍ខ្មែរកម្ពុជាក្រោម និងក្នុងនាមខ្ញុំផ្ទាល់សូមចូលរួមរំលែកទុក្ខដ៏សែនក្រៀមក្រំជាទីបំផុត ជាមួយលោកស្រីជាភរិយា និងក្រុមគ្រួសារសពទាំងមូល ។

លោក សឺន ទូន គឺជាកុលបុត្រខ្មែរកម្ពុជាក្រោមស្នេហាជាតិដ៏ឆ្នើមមួយរូប ដែលបានធ្វើពលីកម្មគ្រប់បែបយ៉ាង ដោយមិនគិតពីការនឿយហត់ក្នុងការតស៊ូដើម្បីទឹកដី និងប្រជារាស្ត្រខ្មែរកម្ពុជាក្រោម ។

មរណៈភាពរបស់លោកសឺន ទូន គឺជាការបាត់បង់នូវបញ្ញាវ័ន្តខ្មែរកម្ពុជាក្រោមស្នេហាជាតិដ៏ឆ្នើមមួយរូបដែលបានយកអស់ពីកម្លាំងកាយ ចិត្ត ប្រាជ្ញា ស្មារតី និងសម្បជញ្ញៈ ខំបំរើជាតិមាតុភូមិដ៏ជាទីស្នេហារបស់យើងរហូតដល់ដង្ហើមចុងក្រោយ ។ រាល់សកម្មភាពដ៏ថ្លៃថ្លានេះ សហគមន៍ខ្មែរកម្ពុជាក្រោមវាយតម្លៃយ៉ាងខ្ពស់ចំពោះឧត្តមគតិវីរភាព គុណបំណាច និងពលីកម្មដ៏ធំធេងរបស់លោក សឺន ទូន ក្នុងបុព្វហេតុតស៊ូដើម្បីជាតិមាតុភូមិកម្ពុជាក្រោម ។

សហគមន៍ខ្មែរកម្ពុជាក្រោម សូមបួងសួងឱ្យវិញ្ញាណក្ខន្ធរបស់លោកសឺន ទូន បានទៅសោយសុខក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ ។

សូមលោកស្រី និងក្រុមគ្រួសារសព មេត្តាទទួលនូវមនោសញ្ចេតនាចូលរួមមរណទុក្ខដ៏ជ្រាលជ្រៅបំផុត អំពីខ្ញុំ ។

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៧

នាយកប្រតិបត្តិសហគមន៍ខ្មែរកម្ពុជាក្រោម

**ថាច់ សេដ្ឋា**

អតីតសមាជិកព្រឹទ្ធសភា

ផ្ទះលេខ ៣២ ផ្លូវលេខ ៤៣២ ក្រុមទី ៣៤ សង្កាត់ទួលទំពូង ១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ
# 32, Street 432, Group 34, Sangkat Toul Tumpoung I, Khan Chamcar Mon, Phnom Penh, Cambodia.
Fax/Phone: 023 220 564 E-mail: kkkco@bigpond.com.kh